# គោលជំហរពិត គំនិតជាពុទ្ធិវិស័យ

*ភាពសំខាន់ចំពោះការយល់ដឹងរឿងភាសា*

*ភាសានិយាយ* មានការអភិវឌ្ឍន៍ឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ ហើយការអភិវឌ្ឍន៍នេះ ជួនកាលមានភាពជាវិជ្ជមាន តែជួនកាលមានភាពជាអវិជ្ជមាន។ ភាសាគឺជាឧបករណ៍ចាំបាច់មួយក្នុងការកំណត់ជោគវាសនារបស់មនុស្សយើងម្នាក់ៗ។ ដូច្នេះ ការយល់ឲ្យបានច្បាស់និងអាចយកភាសាទៅប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព គួរតែស្វែងយល់លក្ខណៈយល់ខុសនៃភាសាខ្មែរខ្លះ ដូចដែលនឹងលើកមកអធិប្បាយដូចតទៅនេះ

## កម្ម

**កម្ម** ជាពាក្យសំខាន់មួយដែលខ្មែរយើងស្គាល់និងប្រើប្រាស់ច្រើនជាងគេ។ ខ្មែរយើងភាគច្រើនយល់ថាកម្មជាគំនាបមួយធ្វើឲ្យខ្មែរជួបប្រទះតែសេចក្តីទុក្ខសោក សង្គ្រាមក្នុងស្រុកជាពិសេសពួកគេម្នាក់ៗ។ ពេលធ្វើអ្វីមិនបានសំរេចឬជួបប្រទះឧបទ្ទវហេតុផ្សេងៗ។ ច្រើនស្តីបន្ទោសទៅលើកម្មរបស់ខ្លួន។ ការយល់ដូច្នេះ ជាការសំដៅទៅលើពាក្យកម្មថាជារបស់ *អាក្រក់ មិនប្រសើរ មិនមានសុពលភាព និងមិនគួរជាទីចង់បាន។*

តាមពិតនេះជាការយល់ខុសមួយធំណាស់ ហើយការយល់ខុសចំពោះកម្មនេះ បានគ្របសង្កត់ចិត្តវិញ្ញាណសង្គមខ្មែរអស់រយៈពេលរាប់សតវត្សន៍មកហើយ។ ជួនកាលពួកបរទេសឆ្លៀតប្រើពាក្យនេះដើម្បីគ្របសង្កត់កំឡាំងសតិបញ្ញានិងការតស៊ូរបស់ខ្មែរយើងមិនឲ្យងើបមុខរួច ។

ការយល់ថាកម្មជារបស់អាក្រក់ ហើយមានលក្ខណៈអវិជ្ជមានជាការខុសទាំងស្រុងទៅនឹងអត្ថន័យពាក្យដើមរបស់កម្ម និងតួនាទីរបស់ពាក្យនេះ ។

**កម្ម** ជាភាសាបាលី ឬ **កម៌** ជាភាសាសំស្ក្រឹត ដែលមានន័យជាភាសាខ្មែរថា អំពើឬការប្រព្រឹត្ត។ កម្មជាពាក្យកណ្តាល។ មិនបានសំដៅថាជាល្អឬអាក្រក់ឡើយ។

ពេលយើងប្រើពាក្យថា **កុសលកម្ម**[1] សំដៅទៅលើកម្មណាដែលល្អ នាំមកនូវសេចក្ដីសុខ បើយើងនិយាយថា**អកុសលកម្ម** សំដៅទៅលើកម្មណាដែលអាក្រក់ នាំមកនូវសេចក្ដីទុក្ខ។

*តើស្រុកខ្មែរយើងជួបប្រទះតែសង្គ្រាម ព្រោះបណ្ដាលមកពីកម្មមែនឬទេ?*

- ការនិយាយដូច្នោះគឺមិនត្រឹមត្រូវទេ ព្រោះកម្មមិនបានធ្វើឲ្យកើតសង្គ្រាម ឬសន្តិភាពដែរ លុះត្រាណាតែយើងប្រព្រឹត្តអំពើជាកុសលកម្ម ឬ អកុសលកម្ម ទើបផលឬវិបាកកើតឡើង។ ដូច្នេះសំណួរឬចំងល់ដែលត្រឹមត្រូវ យើងគួរសួរខ្លួនឯងថា តើស្រុកខ្មែរយើងជួបប្រទះតែសង្គ្រាម ព្រោះបណ្ដាលមកពីយើងប្រព្រឹត្តអកុសលកម្មច្រើនមែនឬទេ?

ពិតណាស់ការនិយាយដូច្នោះ ហាក់ដូចជាដាក់ទោសខ្លួនឯង ប៉ុន្តែយើងត្រូវដឹងថា មកពីខ្មែរយើងនិយមជឿទៅលើព្រហ្មលិខិតជាងកម្មលិខិត ទើបនាំមកនូវវាសនាអាក្រក់ជាបន្តបន្ទាប់។ កត្តាដែលខ្មែរយើងរាល់រូបមិនបានព្យាយាមស្វះស្វែងសិក្សាស្រាវជ្រាវអភិវឌ្ឍន៍ចំណេះដឹងនិងសតិបញ្ញា បញ្ចៀសខ្លួនឲ្យផុតពីគ្រោះអវិជ្ជា នោះឯងជាការប្រចាំងនឹងច្បាប់នៃទ្រឹស្ដីកម្មផល ។

តើកម្ម និង កម្ពុជាដូចគ្នាឬខុសគ្នាយ៉ាងណា?

- មានខ្មែរយើងមួយភាគខ្លះដែលគិតថាកម្ពុជាជួបភ័យវិបត្តិ ពីព្រោះតែកម្មរបស់ខ្លួន ហើយរហូតដល់បន្ទោសថាមកពីយើងមានឈ្មោះប្រទេសថា **កម្ពុជា** គឺមានកម្មរហូត។ តាមសេចក្ដីពិតកម្ពុជាមិនមែនកម្មនោះទេ កម្ពុជាគឺទឹកដីឬប្រទេសមួយដែលកើតមកពីឥសី **ឈ្មោះកម្ពុ** រៀបអភិសេកជាមួយ **នាងមេរា** ទើបកើត

*១. សំដៅទៅលើកុសលកម្ម១០ មានដូចជា : - កាយកម្ម៣(១.សំឡាប់សត្វ, ២.លួចទ្រព្យអ្នកដទៃ, ៣.ប្រព្រឹត្តខុសផ្លូវ ភេទ), វចីកម្ម៤(៤.និយាយកុហក, ៥.និយាយញុះញង់បំបែកបំបាក់គេ, ៦.និយាយពាក្យអសុរស, ៧.និយាយពាក្យឥតប្រយោជន៍) និងមនោកម្ម៣(៨.គិតតែសំឡឹងចង់បានទ្រព្យអ្នកដទៃ, ៩.គិតតែព្យាបាទគេ, ១០.មានសេចក្ដីយល់ឃើញខុស)។*

ជាកម្ពុជាឡើង។ ឬម្យ៉ាងវិញទៀតអាចមានន័យថា ទឹកដីដែលសំបូរទៅដោយមាស និង ពេជ្រ ។

*កម្ម តាមន័យលោកុត្តរធម៌*

ន័យពិតដែលបញ្ជាក់នូវវាលវដ្តសង្សារ ការកើតចាស់ឈឺស្លាប់ គឺបណ្តាលមកពី **កិលេស កម្ម និងវិបាក**។ កាលណាយើងមានកិលេសបណ្តាលឲ្យយើងធ្វើនូវកម្ម កាលណាយើងមានកម្ម ធ្វើឲ្យយើងទទួលនូវផលគឺវិបាក។ ដូច្នេះព្រះអរហន្តទាំងឡាយបានប្រើប្រាស់នូវកម្មជាកុសលដើម្បីជាវិធីកំចាត់នូវកិលេសទាំងពួង។ ពេលកិលេសទាំងអស់ត្រូវបានដួសឲ្យជ្រះស្រឡះហើយ វាលវដ្តសង្សារក៏ត្រូវបានបញ្ចប់ ព្រះនិព្វានក៏ត្រូវបានសំរេច ។

## វេទនា

ពុទ្ធសាសនិកជនខ្មែរយើង ពេលនិយាយឬនឹកដល់វេទនា តែងតែគិតថាជាសេចក្តីទុក្ខដែលនេះជាអភិវឌ្ឍន៍ផ្តត់គំនិតទៅរកភាពខុស ប្រាសចាកការយល់តាមសភាវពិតរបស់វា។ តាមពិតវេទនាមានន័យដោយសព្វថា *ការសោយនូវអារម្មណ៏ដែលមកប៉ះទង្គិចនឹងចិត្តរបស់យើង*។ ជាក់ស្តែងពេលណាមានអារម្មណ៏មិនសប្បាយចិត្ត ទុក្ខក្រៀមក្រំ អន្ទះអន្ទែង មួរម៉ៅសោកសង្រេង **ហៅថាទុក្ខវេទនារម្មណ៏**។ តែពេលណាយើងមានអារម្មណ៏សប្បាយ ធូរស្រាលក្នុងចិត្ត ពេញចិត្ត មានបីតិសោមនស្សរីករាយ ហៅថា**សុខវេទនារម្មណ៏**។ តែជួនកាល យើងហាក់បីដូចជាមិនកើតទុក្ខហើយក៏មិនសប្បាយចិត្តដែរ មានអារម្មណ៏ជាធម្មតា។ តាមសភាវៈពិតនៃធម្មជាតិ នេះហៅថា **ឧបេក្ខារម្មណ៏**(អទុក្ខមសុខរម្មណៈ)។

ដើម្បីឲ្យជាប្រយោជន៏ច្រើន និងអភិវឌ្ឍន៏កំរិតសតិបញ្ញាឲ្យកាន់តែខ្ពស់ឡើយ ពុទ្ធសាសនិកជនខ្មែរ ត្រូវតែយល់នូវនិយមន័យពិតប្រាកដរបស់វេទនានេះឲ្យបានច្បាស់លាស់ ដូចជាពាក្យថាកម្មនោះផងដែរ។

# លះបង់សុខតូច ដើម្បីឈោងចាប់យកសុខធំ

វិស័យពុទ្ធសាសនិកជនគឺជាអ្នកភ្ញាក់រលឹកជាប់ជានិច្ច ហើយជាអ្នកមើលឃើញសេចក្ដីចំរើននិងភាពត្រឹមត្រូវជាធំ។ តាមគំរូព្រះពុទ្ធបរមគ្រូ រាប់ចាប់ពីព្រះអង្គកើតជាព្រះពោធិសាត់ រហូតជាតិចុងក្រោយជាព្រះសិទ្ធត្ថកុមារ ព្រះអង្គរមែងធ្វើការបរិច្ចាគទាន ដែលយើងជាបុថុជ្ជន ឬជាជនសាមញ្ញធម្មតាមិនអាចធ្វើបាន ។

កាលជាតិជាព្រះវេសន្តរ ព្រះអង្គបានធ្វើអនុបារមីទាន ដោយបរិច្ចាគបុត្រាបុត្រីគួរជាទីស្រឡាញ់ពេញចិត្តទៅឲ្យស្មូមជជក់។ ព្រះវេសន្តរមានសេចក្ដីស្រឡាញ់ អាណិតអាសូរព្រះរាជបុត្រយ៉ាងខ្លាំង តែធ្វើម្ដេចបានទៅ បើព្រះអង្គមិនធ្វើដូច្នោះ ភាពជាបរមគ្រូនៃទេវតានិងមនុស្សទាំងឡាយ ឬភាពជាព្រះសម្មាសម្ពុទ្ធៈ ដើម្បីជួយស្រោចស្រង់សត្វលោកទាំងចក្រវាឡមិនអាចប្រព្រឹត្តទៅរួចបានទេ ។

រហូតជាតិជាចុងក្រោយជាព្រះសិទ្ធត្ថកុមារ ព្រះអង្គមានភាពអាឡោះអាល័យចំពោះព្រះរាហុលកុមារដែលជាបុត្រា និងនាងពិម្ពារជាអគ្គមហេសីយ៉ាងខ្លាំង តែធ្វើម្ដេចកើត បើព្រះអង្គមិនដាច់ចិត្តចេញចាកទៅសាងព្រះផ្នួសទេ ព្រះអង្គមិនអាចសំរេចជាព្រះពុទ្ធបានឡើយ។ បើមិនបានត្រាស់ជាព្រះពុទ្ធទេ ក្រុមគ្រួសារញាតិវង្ស សត្វលោកទាំងឡាយ និងកើត ចាស់ ឈឺ ស្លាប់ ដែលជាអណ្ដូងត្រាំនៃទឹកភ្នែកនិងសេចក្ដីទុក្ខ នៅតែមានគ្មានថ្ងៃណាស្រាកស្រាន្តឡើយ ។

ប្រការដែលព្រះវេសន្តរបរិច្ចាគបុត្រាបុត្រីជាទានបារមី ឬការដែលព្រះអង្គចេញទៅសាងព្រះផ្នួសចោលបុត្រានិងអគ្គមហេសី *មិនមែនមានន័យថាព្រះអង្គមិនស្រឡាញ់បុត្រាភរិយាក្រុមគ្រួសារនោះទេ ព្រះអង្គមានសេចក្ដីស្រឡាញ់ប្រកបដោយមេត្តាករុណាជ្រាលជ្រៅ តែនេះជាកាតព្វកិច្ចរបស់ព្រះពុទ្ធទាំងឡាយ ដែលមិនដែលគិតដូចបុថុជ្ជនអ្នកគ្មានបញ្ញានោះទេ ព្រះអង្គសុខចិត្តលះបង់អ្វីៗទាំងអស់សូម្បីតែសម្បត្តិទ្រព្យ តំណែងបុណ្យសក្ដិ បុត្រភរិយា*

*និងជីវិតរបស់ព្រះអង្គផ្ទាល់ក៏ដោយ ដើម្បីបានប្រយោជន៍ធំ ហើយទើបជួយស្រោចស្រង់សត្វលោកនិងព្រះញាតិវង្សជាក្រោយ ។*

ចំណែកអ្នកដែលគិតថា ព្រះពុទ្ធអង្គចេញទៅសាងព្រះផ្នួសមិនមានទឹកចិត្តស្រឡាញ់ កូន ភរិយា និងក្រុមគ្រួសារនោះ គ្រាន់តែជាការវាយប្រហារដោយការយល់មិនដល់ ខ្វះសតិបញ្ញា ឬការគិតឃើញតាមបែបមនុស្សដែលប្រកបដោយ**លោភៈ ទោសៈ និងមោហៈ** ហើយបុគ្គលដែលនិយាយនោះមិនអាចលះបង់សេចក្ដីសុខផ្ទាល់ខ្លួនដើម្បីសេចក្ដីសុខអ្នកដទៃបាន ឡើយ ។

វិស័យពុទ្ធសាសនិកជនពិតប្រាកដគឺដូច្នេះៈ ត្រូវតែហ៊ានធ្វើពលីកម្ម ត្រូវតែភ្ញាក់រលឹក និងអភិវឌ្ឍន៍ខ្លួនជានិច្ច។ អភិវឌ្ឍន៍ខ្លួនពីភាពជាអ្នកសុំទានគេ ទៅជាមនុស្សដែលអាចជួយខ្លួនឯងបាន, អភិវឌ្ឍន៍ពីភាពជាអ្នកធ្វើកម្មករទៅជាចៅកែគេ, អភិវឌ្ឍន៍ពីជនអវិជ្ជាទៅជាជនអ្នកត្រាស់ដឹង និងអភិវឌ្ឍន៍ពីសាមញ្ញជនឲ្យទៅជាអរិយជនជាដើម ។

## ពន្លឺពុទ្ធធម៌រះនៅទិសខាងលិច

ព្រះពុទ្ធធម៌បានផ្សព្វផ្សាយទៅគ្រប់ទិសទីទៅហើយ បុគ្គលណាក៏ដោយ គ្រួសារណាក៏ដោយ ប្រទេសណាក៏ដោយដែលមានសន្តិភាព មានមេត្តាករុណាធម៌ មានខន្តិធម៌ និង អហឹង្សធម៌ មានន័យថាបុគ្គលនោះ ក្រុមគ្រួសារនោះ ប្រទេសនោះមានព្រះពុទ្ធធម៌ជាត្រីវិស័យសំរាប់ពួកគេ ។

ព្រះពុទ្ធធម៌ តាមន័យដើមរបស់វានិងតាមគោលបំណងនៃការប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ គឺមិនមែនមានន័យថា ទាល់តែបុគ្គលជាពុទ្ធសាសនិកជនទើបហៅថាអ្នកមានពុទ្ធធម៌នៅក្នុងលេះដូងនោះទេ ទោះបីអ្នកជាបុគ្គលមានជំនឿបែបណា មានពិណសំបុរនិងភាសាបែបណា តែអ្នកជាបុគ្គលដែលជឿបុណ្យជឿបាប ជឿទៅលើកម្ម ជឿទៅផលនៃកម្ម ជឿថាមានកម្មជារបស់ខ្លួន ជឿទៅលើហេតុផល ងាយនិយាយគ្នា ស្តាប់គ្នាបានតាមភាសារបស់មនុស្ស បុគ្គលនោះមានឈ្មោះថា មាន**ព្រះពុទ្ធធម៌នៅក្នុងចិត្តរបស់ខ្លួន** ។

ជាក់ស្តែងនៅប្រទេសលោកខាងលិច ដែលមានការរីកចំរើនខ្លាំងខាងលទ្ធិប្រជាធិបតេយ្យ សេដ្ឋកិច្ច និងភាពទាន់សម័យនៃគ្រឿងឧបភោគបរិភោគ គេទាំងអស់គ្នានោះមិនថាឡើយជាមនុស្សឬសត្វទេ ហាក់ដូចជាមានសីល មានធម៌អាថិនៅក្នុងខ្លួនជាប់ជានិច្ច។

ប្រជាជនស្រុកគេភាគច្រើនទាំងក្មេង ទាំងចាស់ មានភាពថ្លៃថ្នូរ ចេះគោរពគ្នាទៅវិញទៅមក មានភាពស្មោះត្រង់ កាយវិការអោនលំទោន ពាក្យសំដីមានរាក់មានរៅ ចេះថ្លឹងថ្លែងអ្វីគួរនិយាយអ្វីមិនគួរនិយាយ និងមានមេត្តាករុណាចំពោះសត្វធាតុទាំងឡាយ។ ចំណែកក្មេងៗទាំងឡាយចេះស្រឡាញ់សត្វដូចស្រឡាញ់ជីវិតរបស់ខ្លួនដូច្នោះឯង។ នេះសបញ្ជាក់នូវការប្រកាន់ខ្ជាប់ខ្ជួននូវសីលប្រាំតាំងពីវ័យកុមារភាពមកម្លេះ ។

ចំណែកសត្វវិញ ជាពិសេសគឺសត្វឆ្កែនិងឆ្មា មិនដែលឃើញមានជំលោះដេញខាំឈ្លោះប្រកែកគ្នាទេ។ ពាងឆ្កែនឹងឆ្កែក៏មានមិត្តភាពល្អចំពោះគ្នាទៅវិញទៅមក ពាងឆ្មានិងឆ្មាក៏ដូចគ្នា ហើយពាងឆ្កែនិងឆ្មាក៏ដូចគ្នា ។

បើយើងធ្វើដំណើរទៅក្នុងចំណោមហ្វូងមហាជន នៅតាមសាលារៀនក្តី មន្ទីរពេទ្យក្តី មន្ទីររាជការសាធារណៈ និងការិល័យផ្សេងៗក្តី ការនិយាយពីព្រះពុទ្ធឬប៊ុតដា(**Buddha**) ដែលប្រែថាអ្នកត្រាស់ដឹង មានភាពទូលំទូលាយ ហើយក៏មិនមានមន្ទិលគ្នាន់គ្នេរអ្វីឡើយ។ ព្រោះគួរកត់សំគាល់ថា នៅប្រទេសសេរីនៃលោកខាងលិចទាំងឡាយ ការនិយាយពីអាទិទេព ឬហ្គត់(**God**) មិនសមរម្យនៅតាមតំបន់សាធារណៈទេ។ ជាពាក្យមួយដែលហាក់ដូចជាមានឥទ្ធិពលអាក្រក់សំរាប់សាធារណជនទូទៅ ជាពិសេសប្រទេសដែលមានភាពជាពហុវប្បធម៌ចំរុះទៅដោយជាតិសាសន៍និងជំនឿផ្សេងៗ(**multiculturalism or cosmopolitism**)។

ទាំងអស់នេះគឺជីវិតរស់នៅប្រចាំថ្ងៃ ដែលគេទាំងអស់គ្នានោះហាក់បីដូចជាមានគោលពុទ្ធធម៌នៅពេញក្រអៅបេះដូងរបស់ពួកគេ ។

**ចំណែករឿងនយោបាយវិញ** ប្រទេសទាំងអស់នោះបដិបត្តិដោយយកច្បាប់ជាធំ។ មន្ត្រីរាជការ នគរបាល យោធា នាយករដ្ឋមន្ត្រី និងប្រធានាធិបតេយ្យ គ្រាន់តែជាអ្នកបំរើប្រជាជនតែប៉ុណ្ណោះ។ ពេលធ្វើដំណើរទៅសួរសុខទុក្ខប្រជាជន ឬទៅចូលពិធីបុណ្យណាមួយ។ មិនចាំបាច់មានអង្គរក្សច្រើងស្តាំ កំរាលព្រំអ្វីទេ។ ជីវិតរបស់ពួកគេទាំងអស់នោះគឺសាមញ្ញជាងប្រជាជនធម្មតាទៅទៀត។ ការបដិបត្តិដូចនេះ គឺជាគោលការណ៍នៃពុទ្ធធម៌ ដែលព្រះពុទ្ធអង្គបានគូសវាស់និងដាក់គោលដៅដូច្នោះ ។

**ចំណែករឿងសេដ្ឋកិច្ចវិញ** ប្រទេសទាំងអស់នោះបដិបត្តិសេដ្ឋកិច្ចបែបតំរូវការភាពចាំបាច់ដូចព្រះពុទ្ធសាសនាដែរ។ គឺការមានបច្ច័យបួនប្រើប្រាស់គ្រប់គ្រាន់ **ដូចជាសំលៀកបំពាក់ ម្ហូបអាហារអនាម័យ ផ្ទះសំបែងរស់នៅសមរម្យ និងថ្នាំរក្សាព្យាបាល** ត្រូវតែរកមកជូនប្រជាជនឲ្យបាន។ ហើយសល់ពីនេះ ដូចជាឡាន វិលឡា មាសពេជ្រកែវកង វត្ថុទាន់សម័យ

ឬវត្ថុមានតំលៃផ្សេងៗទៀត ទុកឲ្យបុគ្គលម្នាក់ៗ គេខិតខំស្វែងរកដោយខ្លួនគេចុះ។ នេះជាសេដ្ឋកិច្ចមូលដ្ឋាន ឬ ភាពចាំបាច់របស់ជីវិតដែលព្រះពុទ្ធអង្គបានរៀបចំឡើង ហើយរដ្ឋបុរាណផ្សេងៗនៅសម័យនោះបានយកទៅបដិបត្តិថែមទៀតផង។ សព្វថ្ងៃប្រទេសក្នុងពិភពលោកទាំងឡាយបានកំពុងអនុវត្តទ្រឹស្តីសេដ្ឋកិច្ចបែបបច្ច័យបួនតាមទ្រឹស្តីព្រះពុទ្ធសាសនានេះ។

## រឿងព្រះគោព្រះកែវ, តេជោតំដិន ឬ ពុទ្ធទំនាយ
## បរិបទខាងមនោគមបរទេស ឬ ជាអក្សរសិល្ប៍របស់ខ្មែរ ?

ខ្មែរយើងធ្លាប់ជាអាណាចក្ររុងរឿងដែលពោរពេញទៅដោយចំណុចខ្លាំងនិងចំណុចខ្សោយ។ វាជាធម្មតាទេ មនុស្សដែលថាខ្លួនឯងពូកែឬខ្លាំង តែងតែមានចំណុចខ្សោយស្ថិតនៅក្នុងខ្លួនរបស់ពួកគេ។

យុទ្ធសាស្ត្រការធ្វើសង្គ្រាម ក៏ដូចជានយោបាយឈ្នះៗរបស់គូបដិបក្ខ តែងតែរកចំណុចខ្លាំងចំណុចខ្សោយរបស់ដៃគូខ្លួន។ ខ្មែរយើងបានប្រឈមមុខនូវជុំពពកខ្មៅបក់ផាត់មកយ៉ាងខ្លាំងម្តងហើយម្តងទៀត ដែលសេចក្តីទុក្ខក្រៀមក្រំទាំងនោះកើតឡើងពីការចុះចាញ់ទាំងសង្គ្រាមកំឡាំងបាយ កំឡាំងព្យាយាម កំឡាំងសតិបញ្ញា និងកំឡាំងចិត្តសាស្ត្រមនោគមវិទ្យា។

ពេលនេះយើងល្បងពិចារណាសិក្សាទៅលើសង្គ្រាមមនោគមវិទ្យាមើល៍ តើមានកលឧបាយណាមួយដែលយើងធ្លាប់ចាញ់ ហើយនៅមានជាបន្តរហូតមកដល់បច្ចុប្បន្ននេះ? ។

នៅសម័យលង្វែក យើងធ្លាប់ចាញ់ឧបាយកលព្រះសង្ឃថៃពីរអង្គដែលអះអាងថាព្រះពុទ្ធរូបអង្គធំនៅលង្វែកជាអ្នកបណ្តាលឲ្យប្រជារាស្ត្រនិងនាម៉ឺនមន្ត្រីឈឺ និងមានរោគរាតត្បាត រួចព្រះមហាក្សត្រក៏បញ្ជាឲ្យគេយកទៅទំលាក់ចោលក្នុងទឹកទន្លេ។ នៅពេលស្តេចនរេសូរមិនអាចវាយលុកចូលទៅក្នុងក្រុងលង្វែកបាន គេក៏បានធ្វើឧបាយបាញ់ប្រាក់ដួងចូលទៅក្នុងព្រៃឫស្សី ហើយក៏ដកទ័ពថយទៅ។ ខ្មែរយើងនឹកថាសៀមលែងមកទៀត ហើយព្រោះតែភាពក្រីក្រ ក៏នាំគ្នាត្រួសកាប់ឆ្ការព្រៃឫស្សីយកប្រាក់ដួងនោះមកប្រើ រហូតដល់ទីក្រុងលង្វែកគ្មានរបងការពារ ហើយធ្លាក់ទៅក្នុងកណ្តាប់ដៃសៀមនៅទីបំផុត ។

នេះគ្រាន់តែជាឧទាហរណ៍ខ្លះ ដើម្បីឲ្យប្រជានុរាស្ត្រខ្មែរល្បងសិក្សាមើល៍អំពីរឿងនិងពាក្យពេជន៏ដូចតទៅនេះ

~ រឿងពុទ្ធទំនាយ ឥន្ទទំនាយ តើជារឿងឲ្យខ្មែរយើងកាប់បំពង់រង់ចាំទឹកភ្លៀងឬទេ?

- រឿងព្រះគោ ព្រះគោកែវ និងរឿងតេជោតំដិនជាដើម តើអាចជារឿងបង្កើតជំនឿអរូបីយ៍មហិទ្ធិឫទ្ធិក្នុងប្រយុទ្ធតស៊ូជាខ្មាំងសត្រូវឬទេ?
- ពាក្យថាបាងកករលំ ភ្នំពេញរលាយ ព្រៃនគរខ្ចាត់ខ្ចាយ សប្បាយអង្គរវត្ត តើអាចជាពាក្យពេជ្របន្ទុចបង្អាក់មិនឲ្យមានការងើបឡើងតស៊ូឬទេ?
- កូនចៅអើយ ចូរដាំដើមល្វ ធ្វើគធ្វើថ្លង់ តើអាចជាឧបាយកលមិនឲ្យខ្មែរនិយាយស្ដី និងងើបឡើងតស៊ូឬទេ?

សំណួរខាងលើនេះ គ្រាន់តែគំរុយទុកឲ្យបងប្អូនប្រជាជនខ្មែរទាំងអស់យកទៅគិតនិងពិចារណាដោយខ្លួនឯងចុះ ។